**Declassified to Public**
**12 June 2020**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់បំផុត**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jun-2018, 12:59
CMS/CFO: Ly Bunloung

---

# ដីកាសម្រេចបន្ថែមលើសំណើបន្ទាន់សុំធ្វើការពិចារណា

---

**<u>ផ្ញើជូន៖</u>**

**មេធាវីការពារក្ដី អោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្ដី យឹម ទិត្យ**

សូ មូស្សេទ្ធិ
Suzana TOMANOVIĆ

**អង្គភាពគាំពារការពារក្ដី**

Issac Endeley

# I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះកំណត់ហេតុនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦ មេធាវីការពារក្តី អោ អាន ("មេធាវីការពារក្តី") បានដាក់ *សំណើបន្ទាន់សុំធ្វើការពីចម្ងាយ* ដោយស្នើសុំ ស.ច.ស ចាត់វិធានការដោះស្រាយបញ្ហាលំបាកដែលបានកើតឡើងទាក់ទងនឹងអង្គភាពគាំពារការពារក្តី ("អ.គ.ក") ក្នុងការទូទាត់កម្រៃការងារសម្រាប់អ្នកប្រឹក្សាម្នាក់របស់មេធាវីការពារក្តី ចំពោះការងារដែលបានបំពេញនៅឆ្ងាយពីបរិវេណ អ.វ.ត.ក ("សំណើបន្ទាន់")[1]។

៣. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ យើង Micahel Bohlander បានស្នើសុំប្រធានអ.គ.ក ជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសំអាងហេតុផ្លូវច្បាប់ដែលរារាំងមិនឱ្យទូទាត់កម្រៃការងារជូនអ្នកប្រឹក្សាច្បាប់ចំពោះការងារដែលបានបំពេញនៅឆ្ងាយពីបរិវេណ អ.វ.ត.ក ("ដីកាសម្រេចជាបឋម")[2]។

៤. នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ ប្រធាន អ.គ.ក បានដាក់របាយការណ៍មួយ ក្នុងនោះ គាត់បានជូនដំណឹងផ្សេងៗជាអាទិ៍ គាត់បានស្នើសុំលក្ខខណ្ឌការងារថ្មីសម្រាប់អ្នកប្រឹក្សាច្បាប់របស់សហមេធាវីទាំងអស់ដែលកំពុងបម្រើការងារនៅ អ.វ.ត.ក ("របាយការណ៍របស់ អ.គ.ក")។ យោងតាមសំណើលក្ខខណ្ឌការងារដែលបានកែសម្រួលនេះ អ្នកប្រឹក្សាច្បាប់អាចត្រូវសហមេធាវីរបស់ខ្លួនអនុញ្ញាតឱ្យធ្វើការពីចម្ងាយ ហើយសហមេធាវីត្រូវបញ្ជាក់ពីការងារដែលបានបំពេញពីចម្ងាយ ដោយធ្វើតារាងម៉ោងការងារជូន អ.គ.ក។ ប្រធាន អ.គ.ក ក៏បានជូនដំណឹងផងដែរថា ដោយសារលក្ខខណ្ឌការងារថ្មីដែលបានស្នើឡើងនេះ ការបញ្ជាក់ពីការ

[1] សំណុំរឿង ០០៤ ឯកសារ D321 *សំណើបន្ទាន់សុំធ្វើការពីចម្ងាយ* ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦។

[2] សំណុំរឿង ០០៤ ឯកសារ D321/1 *ដីកាសម្រេចលើសំណើបន្ទាន់សុំធ្វើការពីចម្ងាយ* ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ កថាខណ្ឌ ៣២។

ទូទាត់កម្រៃការងារសម្រាប់អ្នកប្រឹក្សារបស់មេធាវីការពារក្តី ដែលបច្ចុប្បន្ននេះកំពុងធ្វើការងារពីចម្ងាយនោះ នឹងមិនបណ្តាលឲ្យមានការលំបាកថែមទៀតទេ[3]។

## II. ពិភាក្សា

៥. តាមរយៈព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់ អ.គ.ក មានន័យថា លែងចាំបាច់ ឬក៏តម្រូវឲ្យមានអន្តរាគមន៍ពី ស.ច.ស តាមសំណើដែលបានស្នើសុំនៅក្នុងសំណើបន្ទាន់ទៀតហើយ។ ការសម្រេចបែបនេះនៅតែមានសុពលភាពដដែល ដោយមិនគិតថាតើសហមេធាវីទទួលយកលក្ខខណ្ឌការងារដែលប្រធាន អ.គ.ក បានស្នើឡើងនោះទេ ជាលក្ខខណ្ឌដែលសមហេតុផល និងស្របតាមគោលការណ៍ដែលបានបង្ហាញនៅក្នុងដីកាសម្រេចជាបឋម។

៦. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសំអាងហេតុខាងលើ យើង** Micahel Bohlander ៖

៧. **ប្រកាស** ថា សំណើបន្ទាន់ ត្រូវទុកជាមោឃៈ។

ភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

---

[3] សំណុំរឿង ០០៤ ឯកសារ D321/2 *របាយការណ៍របស់ អ.គ.ក ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ទាក់ទិននឹង"សំណើបន្ទាន់សុំធ្វើការពីចម្ងាយ"របស់ក្រុមមេធាវីការពារក្តី អោ អាន* ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ និងដាក់នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦។